ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៥៨៩ សហវ.ប្រក

# ប្រកាស

## ស្តីពី

## វិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្ម នៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/004 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ស្ដីពីនីតិវិធីនៃការផ្ដល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធាន និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ដោយអនុលោមតាមមាត្រា៩និងមាត្រា២៣ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ តម្លាភាព និងគណនេយ្យភាពនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពគ្របដណ្ដប់លើការអនុវត្តប្រាក់បេសកកម្មទាំងនៅក្នុងនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ រួមទាំងការកំណត់សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មក្នុងប្រទេស។

## ជំពូកទី២

## សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មនៅក្នុងប្រទេស

**ប្រការ៤.-**

សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មនៅក្នុងប្រទេស ត្រូវផ្ដល់ជូនជាសាច់ប្រាក់ អាស្រ័យលើមធ្យោបាយធ្វើដំណើរនិងចម្ងាយនៃការធ្វើដំណើរ ក្នុងការបំពេញបេសកកម្មនៅក្នុងប្រទេស។

ការជ្រើសរើសប្រើប្រាស់មធ្យោបាយធ្វើដំណើរណាមួយ ត្រូវសម្រេចដោយអនុលោមតាមគោលការណ៍វិចារណកម្មចំណាយនិងសន្សំសំចៃ។

ប្រការ៥.-

សោហ៊ុយធ្វើដំណើរ ត្រូវបានកំណត់តាមមធ្យោបាយធ្វើដំណើរ ដូចខាងក្រោម៖

- ក្នុងករណីប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ឬផ្ទាល់ខ្លួន សោហ៊ុយធ្វើដំណើរត្រូវផ្តល់ជូនដូចខាងក្រោម៖
  - សាច់ប្រាក់ចំនួន ៨០ ០០០(ប្រាំបីម៉ឺន) រៀល ក្នុង ១០០ គីឡូម៉ែត្រសម្រាប់រថយន្តមួយគ្រឿង។
  - សោហ៊ុយធ្វើដំណើរត្រូវគណនាជាសាច់ប្រាក់ ទៅតាមចម្ងាយធ្វើដំណើរជាក់ស្តែងតាមគោលការណ៍សមាមាត្រ ធៀបនឹងចំនួនដែលបានកំណត់ខាងលើនេះ។
- ក្នុងករណីប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ សោហ៊ុយធ្វើដំណើរត្រូវផ្តល់ជូនតាមតម្លៃសំបុត្ររថយន្តក្រុង កាណូត ឬកប៉ាល់ ដែលធ្វើដំណើរតាមគោលដៅនៃការបំពេញបេសកកម្ម តាមចំនួនទឹកប្រាក់កត់ត្រាក្នុងវិក្កយបត្រ ឬឯកសារមានលក្ខណៈជាផ្លូវការ។ ការជ្រើសរើសមធ្យោបាយធ្វើដំណើរប្រភេទនេះត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមចំនួន ២០ ០០០ (ពីរម៉ឺន)រៀលក្នុង០១នាក់ ដើម្បីសម្រួលការធ្វើដំណើរបន្តទៅកាន់គោលដៅបេសកកម្ម។
- ក្នុងករណីមិនអាចប្រើប្រាស់មធ្យោបាយធ្វើដំណើរទាំងពីរប្រភេទខាងលើ ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវស្នើសុំគោលការណ៍ជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជួលរថយន្ត ឬជួលមធ្យោបាយធ្វើដំណើរសមស្រប សម្រាប់ការបំពេញបេសកកម្មដូចជា ការធ្វើអធិការកិច្ចឬសវនកម្ម ការសិក្សាស្រាវជ្រាវ ការត្រួតពិនិត្យ ការដ្ឋានសំណង់នានា ការចុះទៅកាន់តំបន់គោលដៅដាច់ស្រយាល។

ប្រការ៦.-

ក្នុងករណីប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ឬផ្ទាល់ខ្លួន សោហ៊ុយធ្វើដំណើរ ដូចមានចែងក្នុងប្រការ៥ខាងលើ ត្រូវផ្តល់ជូនសម្រាប់មធ្យោបាយធ្វើដំណើរចំនួន០១គ្រឿង សម្រាប់បេសកកម្មដែលមានសមាជិក អតិបរមាចំនួន៤នាក់។ ក្នុងករណីសំណល់នៃផលចែករវាងចំនួនអ្នកធ្វើដំណើរសរុបធៀបនឹងឯកតា (ចំនួន៤នាក់/រថយន្ត០១គ្រឿង) មានចំនួនពី០១នាក់ដល់០៣នាក់ សោហ៊ុយធ្វើដំណើរត្រូវផ្តល់បន្ថែមដោយគិតស្មើនឹងមធ្យោបាយធ្វើដំណើរចំនួន០១គ្រឿងទៀត។

ចំពោះសមាជិករាជរដ្ឋាភិបាល ថ្នាក់ដឹកនាំស្ថាប័ន ឬអង្គភាពរដ្ឋបាលថ្នាក់ជាតិ ដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ សោហ៊ុយធ្វើដំណើរត្រូវផ្តល់ជូនដោយគិតស្មើនឹងមធ្យោបាយធ្វើដំណើរចំនួន០១គ្រឿងសម្រាប់០១នាក់។

ប្រការ៧.-

សមាជិករាជរដ្ឋាភិបាល ថ្នាក់ដឹកនាំស្ថាប័ន ឬអង្គភាពរដ្ឋបាលថ្នាក់ជាតិ ដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះមានសិទ្ធិធ្វើដំណើរតាមយន្តហោះក្នុងករណីចាំបាច់។ សោហ៊ុយធ្វើដំណើរបន្តពីព្រលានយន្តហោះទៅដល់គោលដៅ ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមចំនួន ៨០ ០០០(ប្រាំបីម៉ឺន) រៀលក្នុង០១នាក់។

## ជំពូកទី៣
## វិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស
## ផ្នែកទី១
## វិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មក្នុងប្រទេស

**ប្រការ៨.-**

ឥណទានថវិកាសម្រាប់បេសកកម្ម ត្រូវបានអនុញ្ញាតឱ្យចំណាយតាមរជ្ជទេយ្យបុរេប្រទាន ១០០% សម្រាប់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ដែលអនុវត្តថវិកាកម្មវិធី ដោយអនុលោមតាមនីតិវិធីចំណាយដូចខាងក្រោម÷

- នៅរៀងរាល់ដើមឆ្នាំ តាមសំណើរបស់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បើកផ្តល់ថវិការជ្ជទេយ្យបុរេប្រទានសម្រាប់បេសកកម្មក្នុងប្រទេសចំនួន២៥% នៃឥណទានថវិកាសរុបប្រចាំឆ្នាំក្នុងគណនី៦១១២ (សោហ៊ុយបេសកកម្មក្នុងប្រទេស) របស់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ។
- ថវិកាបេសកកម្មរបស់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវបើកផ្តល់ជូននិងគ្រប់គ្រងប្រើប្រាស់ដោយអង្គភាពថវិកា ដែលជាប្រតិបត្តិករនៃកម្មវិធី ឬអនុកម្មវិធីរបស់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ។ ចំពោះក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ដែលមានអង្គភាពថវិកាច្រើនអគ្គនាយកដ្ឋាន ឬនាយកដ្ឋានទទួលបន្ទុកហិរញ្ញវត្ថុ មានភារកិច្ចសម្របសម្រួលការបើកផ្តល់និងទូទាត់ក្នុងនាមក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ចំពោះចំណាយថវិកាបេសកកម្មរបស់រដ្ឋបាលកណ្តាល ។
- ប្រាក់បេសកកម្ម ត្រូវទូទាត់តាមទំហំទឹកប្រាក់ចំណាយជាក់ស្តែង ដោយមិនមានកំណត់ទឹកប្រាក់អតិបរមាក្នុងមួយសក្ខីប័ត្រចំណាយ សម្រាប់ការបំពេញបេសកកម្មមិនលើសពី១០ថ្ងៃ ក្នុងមួយខែ។ ក្នុងករណីមានបេសកកម្ម លើសពីចំនួនថ្ងៃកំណត់ខាងលើ ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវស្នើសុំគោលការណ៍ជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់ពីទទួលបានការឯកភាព ចំណាយជាក់ស្តែងត្រូវប្រើថវិការជ្ជទេយ្យបុរេប្រទាន ដូចករណីបេសកកម្មដែលមានរយៈពេលមិនលើសពី ១០ថ្ងៃដែរ។
- ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ឬមន្ទីរជំនាញរាជធានី ខេត្ត តម្រូវឱ្យភ្ជាប់តែរបាយការណ៍ចំណាយដូចមានគំរូជាឧបសម្ព័ន្ធនៃប្រកាសនេះ ជាមួយអាណត្តិកិច្ច និងសលាកប័ត្រមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយរក្សាទុកសក្ខីប័ត្រដើមនៅអគ្គនាយកដ្ឋាន ឬនាយកដ្ឋានទទួលបន្ទុកហិរញ្ញវត្ថុរបស់សាមីក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងមន្ទីរជំនាញរាជធានី ខេត្ត ជាកម្មវត្ថុនៃការធ្វើអធិការកិច្ចឬសវនកម្ម។ ក្នុងករណីចាំបាច់

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ឬអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈ មានសិទ្ធិស្នើសុំការបញ្ជាក់ ឬ ផ្តល់ឯកសារច្បាប់ដើមពាក់ព័ន្ធបន្ថែម ។

- ការបើកផ្តល់ថវិការដ្ឋទេយ្យបុរេប្រទានសម្រាប់បេសកកម្មក្នុងប្រទេសបន្ទាប់ទៀត ត្រូវធ្វើឡើងក្រោមរូបភាពជាការបំពេញឡើងវិញនូវថវិកាដែលបានចំណាយជាក់ស្តែង ទៅតាមទំហំទឹកប្រាក់ដែលក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិស្នើសុំទូទាត់។
- សរុបទឹកប្រាក់ដែលបានទូទាត់ និងដែលត្រូវទូទាត់ជម្រះរដ្ឋទេយ្យបុរេប្រទាន ត្រូវមានទំហំមិនលើសពីឥណទានថវិកាសរុបក្នុងគណនី ៦១១២ ប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ។

**ប្រការ៩.-**

ចំពោះក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ដែលអនុវត្តថវិកាមិនមែនកម្មវិធី នីតិវិធីនៃការបើកផ្តល់ និងការទូទាត់ប្រាក់បេសកកម្មក្នុងប្រទេសត្រូវបន្តអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុ ដូចមានចែងក្នុងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

អាណាប័កត្រូវដាក់គម្រោងចំណាយទាំងអស់មកអភិបាលហិរញ្ញវត្ថុ ដើម្បីពិនិត្យពីភាពត្រឹមត្រូវនៃកម្មវត្ថុចំណាយ ភាពទំនេរនៃឥណទាន ការកត់ត្រាចំណាយនិងផ្តល់ទិដ្ឋាការធានាចំណាយមុននឹងធ្វើការបើកផ្តល់ប្រាក់បេសកកម្ម។

**ប្រការ១០.-**

មុខចំណាយដែលមានរបបកំណត់ដូចមានចែងក្នុងមាត្រា៧ និងមាត្រា៨នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មិនតម្រូវឱ្យមានវិក្កយបត្រទៀតទេ ប៉ុន្តែ តម្រូវឱ្យភ្ជាប់នូវលិខិតបញ្ជាបេសកកម្ម និង ទិដ្ឋាការធ្វើដំណើរ ដែលមានការបញ្ជាក់ពីអង្គភាពគោលដៅបេសកកម្ម ដែលជាមូលដ្ឋានអត្ថិភាពនៃចំណាយបេសកកម្ម។ ដោយឡែក ការទូទាត់សោហ៊ុយធ្វើដំណើរ ដោយមិនប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ឬផ្ទាល់ខ្លួន និងចំណាយផ្សេងៗ តម្រូវឱ្យមានវិក្កយបត្រ ស្របតាមនីតិវិធីនៃចំណាយថវិការដ្ឋទេយ្យបុរេប្រទាន។

រាល់ការទូទាត់ចំណាយបេសកកម្មក្នុងប្រទេសត្រូវគិតជាប្រាក់រៀល។

**ប្រការ១១.-**

ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវធ្វើវិចារណកម្មលើចំណាយប្រាក់បេសកកម្ម ដោយកាត់បន្ថយជាអតិបរមា នូវចំនួនបេសកកម្មនិងចំនួនថ្ងៃបេសកកម្មមិនចាំបាច់ ឬកម្រិតចំនួនមន្ត្រីបំពេញបេសកកម្មពីថ្នាក់ជាតិ ដោយប្រើប្រាស់មន្ត្រីជំនាញពាក់ព័ន្ធនៅរាជធានី ខេត្តជំនួសវិញ ក្នុងករណីមិនមានការហាមឃាត់ដោយច្បាប់ ឬ បទប្បញ្ញត្តិជាធរមាន។

# ផ្នែកទី២
## វិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មក្រៅប្រទេស

**ប្រការ១២.-**

ការកំណត់តំបន់និងក្រុមប្រទេសតាមតំបន់ សម្រាប់ចំណាយបេសកកម្មក្រៅប្រទេស ត្រូវអនុវត្តតាមតារាងភូមិសាស្ត្រ ស្តីពីឈ្មោះប្រទេសនិងរាជ/រដ្ឋធានី ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ១៣.-**

ការបំពេញបេសកកម្មទៅប្រទេសអាស៊ាន មិនតម្រូវឱ្យមានការស្នើសុំធានាចំណាយជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទេ។ ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់មុនពេលបំពេញបេសកកម្មមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែម្តង ដោយអនុវត្តតាមគោលរបបកំណត់សម្រាប់ប្រាក់ហោប៉ៅ ប្រាក់ហូបចុក និងស្នាក់នៅ ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យលេខ២១៦អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ដោយឡែកតម្លៃសំបុត្រ យន្តហោះត្រូវផ្អែកតាមតារាងថ្លៃ ដែលរៀបចំ និងធ្វើបច្ចុប្បន្នភាពដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ) ដោយប្រើប្រាស់ជើងហោះហើរត្រង់និងសន្សំសំចៃបំផុត។

**ប្រការ១៤.-**

នីតិវិធីចំណាយប្រាក់បេសកកម្មក្រៅប្រទេសក្រៅពីប្រទេសអាស៊ាន ត្រូវអនុវត្តតាមខ្លឹមសារនៃមាត្រា២០ មាត្រា២១ និងមាត្រា២២នៃអនុក្រឹត្យលេខ២១៦អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងនីតិវិធី ដូចខាងក្រោម÷

- អាណាប័កត្រូវស្នើសុំទិដ្ឋាការធានាចំណាយជាមុន ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធសម្រាប់បញ្ជាក់ពីភាពចាំបាច់នៃការធ្វើបេសកកម្ម។ ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវរៀបចំផែនការសកម្មភាពសម្រាប់បំពេញបេសកកម្ម ដោយត្រូវរៀបចំគម្រោងចំណាយឱ្យបានពីចម្ងាយ សម្រាប់រៀបចំនីតិវិធីស្នើសុំគោលការណ៍ធានាចំណាយ និងរៀបចំបោះផ្សាយអាណត្តិបើកប្រាក់។
- ក្នុងករណីក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ បោះផ្សាយអាណត្តិបើកប្រាក់ ដោយមិនបានសុំទិដ្ឋាការធានាចំណាយជាមុន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាននីតិសម្បទាគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យ និងកាត់ចេញជាយថាហេតុ នូវចំណាយថវិកាដែលមិនត្រឹមត្រូវតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុនិងបញ្ជូនអាណត្តិដែលបានបោះផ្សាយរួចត្រឡប់ទៅក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ដើម្បីរៀបចំការបោះផ្សាយអាណត្តិបើកប្រាក់ថ្មីឡើងវិញ។
- ចំណាយបេសកកម្ម ដែលបានទទួលទិដ្ឋាការធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួចហើយ អាណាប័កអាចបោះផ្សាយអាណត្តិបើកប្រាក់ជារបបកំណត់សម្រាប់ផ្តល់ជូនតែម្តង។

ត្រឡប់មកវិញ  អ្នកចុះបេសកកម្មត្រូវបំពេញឯកសារលិខិតយុត្តិការគ្រប់គ្រាន់និងត្រឹមត្រូវសម្រាប់ទូទាត់ជម្រះចំណាយតាមការជាក់ស្តែង។

**ប្រការ១៥.-**

ក្នុងករណីមានការពន្យារពេលបំពេញបេសកកម្មដោយមូលហេតុសត្យានុម័ត ប្រាក់បេសកកម្មអាចផ្តល់ជូនបន្ថែមបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ អាណាប័កត្រូវទទួលខុសត្រូវលើភាពត្រឹមត្រូវនៃលិខិតយុត្តិការចំណាយរបស់គណៈប្រតិភូ រួមទាំងរបាយការណ៍សម្រាប់ជាមូលដ្ឋាននៃការទូទាត់បន្ថែមនេះ ព្រមទាំងត្រូវបញ្ជាក់ពីភាពចាំបាច់និងត្រឹមត្រូវនៃបេសកកម្មដែលពន្យារពេលនោះ។

**ប្រការ១៦.-**

មុខចំណាយសម្រាប់បេសកកម្មក្រៅប្រទេស ត្រូវបានផ្តល់តាមគោលការណ៍ដូចខាងក្រោម÷

- ប្រាក់បេសកកម្ម អាចត្រូវបានអនុញ្ញាតឱ្យគ្រោងបន្ថែមចំនួនពីរថ្ងៃគឺមុនមួយថ្ងៃ និងក្រោយមួយថ្ងៃនៃកម្មវិធីផ្លូវការ។ ករណីដែលជើងហោះហើរត្រូវចេញដំណើរ និងត្រឡប់មកវិញលើសពីពីរថ្ងៃ ត្រូវតែមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់។
- ការធ្វើដំណើរលើយន្តហោះពេលយប់ដែលមិនមានតម្រូវការស្នាក់នៅ នោះសោហ៊ុយស្នាក់នៅមិនត្រូវបានផ្តល់ជូនឡើយ។
- ប្រាក់ហោប៉ៅ និងប្រាក់ហូបចុក មិនត្រូវបានផ្តល់ជូនទេ សម្រាប់ថ្ងៃបំពេញបេសកកម្មដែលចេញដំណើរក្រោយម៉ោង ៦:០០នាទីល្ងាច និងត្រលប់មកដល់វិញមុនម៉ោង៦:០០នាទីព្រឹក។
- មុខចំណាយទាំងឡាយណាដែលត្រូវបានទទួលរ៉ាប់រងពីភាគីអញ្ជើញ មិនត្រូវបានផ្តល់ជូនឡើយ។ ក្នុងករណីដែលរាល់មុខចំណាយទាំងអស់ ជាបន្ទុកទាំងស្រុងរបស់ភាគីអញ្ជើញ មានតែប្រាក់ហោប៉ៅប៉ុណ្ណោះ ដែលត្រូវ ផ្តល់ជូនជាប្រាក់បេសកកម្ម និងមានកម្រិតមិនលើសពី១០(ដប់)ថ្ងៃ។

**ប្រការ១៧.-**

សោហ៊ុយធ្វើដំណើរក្នុងស្រុកនៃប្រទេសគោលដៅបេសកកម្ម ត្រូវផ្តល់ជូនក្នុងករណីមានតម្រូវការចាំបាច់ជាក់ស្តែងប៉ុណ្ណោះ ដោយកំណត់កម្រិតអតិបរមា ដូចខាងក្រោម÷

- ចំនួន ១០០(មួយរយ)ដុល្លារអាមេរិក សម្រាប់ប្រតិភូមានសមាជិកចំនួន០១នាក់
- ចំនួន ១៥០(មួយរយហាសិប)ដុល្លារអាមេរិកសម្រាប់ប្រតិភូមានសមាជិកចំនួន០២នាក់
- ចំនួន៥០(ហាសិប)ដុល្លារអាមេរិក/ក្នុង០១នាក់ សម្រាប់ប្រតិភូមានសមាជិក លើសពីចំនួន០២នាក់។

គណៈប្រតិភូកីឡាករ ឬយុវជន/សិស្ស/និស្សិត និងគណៈប្រតិភូសិល្បករ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់របបកំណត់ខាងលើនេះទេ។ ក្នុងករណីមិនមានការរ៉ាប់រងពីប្រទេសជាភាគីអញ្ជើញ សាមីអង្គភាពត្រូវលើកសំណើសុំថ្នូលមធ្យោបាយសមរម្យ ពេលស្នើសុំធានាចំណាយ។

**ប្រការ១៨.-**

ប្រាក់ចំណាយផ្សេងៗ ត្រូវផ្តល់ជូនក្នុងកម្រិតមួយសមស្រប និងតាមករណីចាំបាច់ ដោយផ្អែកលើគម្រោងរបស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ដែលស្នើសុំចំណាយ។

ប្រាក់ចំណាយលើវត្ថុអនុស្សាវរីយ៍ ត្រូវផ្តល់ជូនចំពោះបេសកកម្មដែលដឹកនាំដោយអគ្គលេខាធិការ អគ្គនាយក ឬមន្ត្រីរាជការសាធារណៈដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះឡើងទៅ ដើម្បីចូលរួមកិច្ចចរចាទ្វេភាគី ឬពហុភាគីតាមការប្រគល់សិទ្ធិរបស់រាជរដ្ឋាភិបាល។ ប្រាក់ចំណាយលើវត្ថុអនុស្សាវរីយ៍ មិនត្រូវផ្តល់ជូនឡើយចំពោះបេសកកម្មផ្សេងទៀត ដូចជាការចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា។

**ប្រការ១៩.-**

ការទូទាត់ចំណាយបេសកកម្មក្រៅប្រទេស តម្រូវឱ្យមានវិក្កយបត្រ ចំពោះសោហ៊ុយធ្វើដំណើរនិងចំណាយផ្សេងៗប៉ុណ្ណោះ។ ចំពោះរាល់មុខចំណាយដែលអត្រាកំណត់ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មិនតម្រូវឱ្យមានវិក្កយបត្រទេ។

ទន្ទឹមនេះ ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវផ្តល់ជូនលិខិតយុត្តិការចំណាយផ្សេងៗដូចជាឯកសារចម្លងនៃលិខិតឆ្លងដែនដែលមានបោះត្រាចេញចូលប្រទេសគោលដៅបំពេញបេសកកម្ម ប័ណ្ណឡើងជិះយន្តហោះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រោយពេលបញ្ចប់បេសកកម្ម យ៉ាងយូរត្រឹមរយៈពេល៣០ថ្ងៃ មកអគ្គនាយកដ្ឋានរតនាគារជាតិ និងរតនាគាររាជធានី ខេត្ត ដើម្បីរក្សាទុក។

**ប្រការ២០.-**

គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវសន្សំសំចៃឥណទានថវិកាសម្រាប់ចំណាយប្រាក់បេសកកម្មទៅក្រៅប្រទេស ដោយត្រូវ ÷

- ប្រើប្រាស់ជើងហោះហើរត្រង់និងសន្សំសំចៃបំផុត
- កាត់បន្ថយសមាជិកឱ្យនៅចំនួនតិចបំផុត
- ស្នើសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ដើម្បីឱ្យស្ថានទូតកម្ពុជាប្រចាំប្រទេសនោះចូលរួមជំនួស
- កក់សំបុត្រយន្តហោះឱ្យបានមុនពីចម្ងាយដើម្បីទទួលបានតម្លៃសំបុត្រថោកជាង និងគួរទិញសំបុត្រយន្តហោះ ពីក្រុមហ៊ុន ឬភ្នាក់ងារទេសចរណ៍ដែលមានការចុះបញ្ជីត្រឹមត្រូវ មានកេរ្តិ៍ឈ្មោះ និងស្នាដៃល្អ និងក្នុងតម្លៃប្រកួតប្រជែង (តម្លៃសមរម្យ)។

**ប្រការ២១.-**

អ្នកបំពេញបេសកកម្ម ត្រូវជ្រើសរើសជើងហោះហើរត្រង់បំផុត។ ក្នុងករណីសាមីខ្លួនជ្រើសរើសជើងហោះហើរឆ្លងកាត់ព្រលានយន្តហោះដែលត្រូវរង់ចាំ ដើម្បីចំណាយពេលវេលាសម្រាប់កិច្ចការឯកជន សាមីខ្លួនត្រូវ

ទទួលខុសត្រូវចំពោះចំណាយបន្ថែមទៅលើមធ្យោបាយធ្វើដំណើរ និងត្រូវទទួលខុសត្រូវចំពោះការប៉ះពាល់ដល់កម្មវិធីបំពេញបេសកកម្ម ឬ ឧបទ្ទវហេតុកើតឡើងជាយថាហេតុ ។

**ប្រការ២២.-**

រាល់បេសកកម្មនៅក្នុងនិងក្រៅប្រទេស ដែលបានអនុវត្តក្នុងឆ្នាំ នៅមិនទាន់បានស្នើសុំទូទាត់ ត្រូវបានអនុញ្ញាតឱ្យទូទាត់ រយៈពេលយ៉ាងយូរបំផុតត្រឹមត្រីមាសទីមួយនៃឆ្នាំបន្ទាប់ ដោយប្រើប្រាស់ឥណទានថវិកាឆ្នាំថ្មី។ ហួសកាលកំណត់នេះ អភិបាលហិរញ្ញវត្ថុមាននីត្យានុកូលភាពគ្រប់គ្រាន់ ក្នុងការបដិសេធការទូទាត់ប្រាក់បេសកកម្ម លើកលែងតែមានការពន្យល់ច្បាស់លាស់ពីមូលហេតុនៃការយឺតយ៉ាវ។

ប្រាក់បេសកកម្មដែលត្រូវបានបុរេប្រទានរួចហើយ នៅមិនទាន់បានទូទាត់ជម្រះ ត្រូវបានអនុញ្ញាតឱ្យទូទាត់ រយៈពេលយ៉ាងយូរបំផុតត្រឹមត្រីមាសទីមួយនៃឆ្នាំបន្ទាប់ ដោយប្រើប្រាស់ឥណទានថវិកាឆ្នាំថ្មី។ ហួសកាលកំណត់នេះ អាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិ នៅតែត្រូវទទួលខុសត្រូវក្នុងការទូទាត់ជម្រះប្រាក់បេសកកម្មដែលបានផ្ដល់បុរេប្រទានជូន ហើយឥណទានថវិកាឆ្នាំថ្មីរបស់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ នឹងត្រូវបានបង្កកតាមទំហំទឹកប្រាក់បុរេប្រទាននោះ ទុកសម្រាប់ការទូទាត់ជម្រះចំណាយ។

ការខកខាន ឬការយឺតយ៉ាវក្នុងការទូទាត់បុរេប្រទានប្រាក់បេសកកម្មតាមកាលកំណត់ ត្រូវជាកម្មវត្ថុនៃការចាត់វិធានការរឹតបន្តឹងនៃការផ្ដល់បុរេប្រទានលើកក្រោយៗទៀត ព្រមជាមួយនឹងការទទួលខុសត្រូវដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**ប្រការ២៣.-**

ការចំណាយលើការប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋឬផ្ទាល់ខ្លួន ដូចមានចែងក្នុងប្រការ៥នៃប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីឆ្នាំ២០១៥តទៅ។ ដោយឡែក ក្នុងឆ្នាំ២០១៤ ចំណាយលើការប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ឬឯកជន អាចផ្ដល់ជូនជាប្រាក់ឬជាប្រេងឥន្ធនៈអាស្រ័យតាមលទ្ធភាពនៃថវិកាដែលក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ បានគ្រោងក្នុងកញ្ចប់ឥណទានថវិកាប្រចាំឆ្នាំ។

**ប្រការ២៤.-**

សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី ប្រការ៨នៃប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីឆ្នាំ២០១៥តទៅ។ ដោយឡែក ចំពោះការបើកផ្ដល់ និងការទូទាត់ប្រាក់បេសកកម្មក្នុងប្រទេសក្នុងឆ្នាំ២០១៤ ត្រូវបន្តអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុដូចមានចែងក្នុងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ និងបទប្បញ្ញត្តិហិរញ្ញវត្ថុពាក់ព័ន្ធជាធរមាន។

## ជំពូកទី៥

## ទោសប្បញ្ញត្តិ

**ប្រការ២៥.-**

មន្ត្រីរាជការសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈ រួមទាំងមន្ត្រីជាប់កិច្ចសន្យា ត្រូវទទួលទណ្ឌកម្មរដ្ឋបាល តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ដោយមិនគិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី ចំពោះសកម្មភាព ដែលបានប្រព្រឹត្ត ឬសមគំនិតក្នុងការប្រព្រឹត្ត ដូចខាងក្រោម÷

- ការក្លែងបន្លំលិខិតយុត្តិការចំណាយ និងលិខិតស្នាមផ្សេងៗ ក្នុងគោលបំណងទទួលបានប្រាក់បេសកកម្ម ដែលខ្លួនពុំមានសិទ្ធិទទួលតាមបទប្បញ្ញត្តិជាធរមាន
- ការបង្វែរ ឬកេងប្រវ័ញ្ចប្រាក់បេសកកម្ម ដើម្បីយកទៅប្រើប្រាស់ក្រៅពីការបំពេញបេសកកម្ម
- ការបង្កើនរយៈពេលបំពេញបេសកកម្ម និង/ឬ ចំនួនមន្ត្រីចុះបេសកកម្ម ដែលខុសពីបេសកកម្មដែលបាន អនុវត្តជាក់ស្ដែង
- ការបង្កើតបេសកកម្មដោយក្លែងបន្លំ ក្នុងគោលបំណងទទួលបានប្រាក់ឧបត្ថម្ភបន្ថែម
- ការទទួលបានប្រាក់បេសកកម្មតែមិនបានផ្ដល់ជូនសាមីមន្ត្រីរាជការសាធារណៈដែលត្រូវបំពេញ បេសកកម្ម
- ការរារាំង ឬការព្យាយាមរារាំង ដល់ដំណើរការត្រួតពិនិត្យប្រក្រតីភាពនៃការអនុវត្តប្រាក់បេសកកម្ម។

**ប្រការ២៦.-**

អនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ទណ្ឌកម្មរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល រួមមានជាអាទិ៍÷

- ការស្ដីបន្ទោស
- ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ
- ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស
- ការបន្ថយឋានន្តរស័ក្តិឬថ្នាក់
- ការដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់
- ការបញ្ឈប់ពីការងារដោយបង្ខំ ឬការបណ្ដេញចេញពីមុខតំណែងជាមន្ត្រីរាជការ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ២៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ ឆ្នាំ២០១៤

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ
- សាលារាជធានី ខេត្ត
- ដូចប្រការ២៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*ពាក់ព័ន្ធឧបសម្ព័ន្ធប្រកាសផ្នែកប្រកាសស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ*

ក្រសួង :................................

អគ្គនាយកដ្ឋាន:......................

នាយកដ្ឋាន:..........................

# តារាងរបាយការណ៍ចំណាយប្រាក់បេសកកម្មចាប់ពីថ្ងៃទី..... ខែ....... ឆ្នាំ២០១.. ដល់ថ្ងៃទី...... ខែ..... ឆ្នាំ២០១.....

## តារាងក

| លរ | នាមនិងគោត្តនាម | លិខិតបេសកកម្ម | | កម្មវត្ថុនៃការចុះបេសកកម្ម បំពេញបេសកកម្មភាព | ទីកន្លែង | កាលបរិច្ឆេទចុះបេសកកម្ម | |
|---|---|---|---|---|---|---|---|
| | | លេខ | កាលបរិច្ឆេទ | | | ចាប់ផ្តើម | គ្រឡ |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

រាជធានីភ្នំពេញ, ថ្ងៃទី... ខែ.... ឆ្នាំ.....

បានឃើញ និងឯកភាព

រដ្ឋមន្ត្រី/ប្រធានស្ថាប័ន/ ប្រធានអង្គភាព

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ

ប្រធានការិយាល័យគណនេយ្យ